ទំនុកដំកើង១២០-១២៣

# ជំពូក ១២០

***ឆាកចនា*** *ជីវិតរស់នៅនៃជនពនេចរ*

យើងសិក្សាឈុតទំនុកដំកើងមួយសំណុំទៀត ពីជំពូក១២០-១៣៤។ កន្សោមជំពូកទាំងអស់នេះមានដប់ប្រាំជំពូក។ ចំណងជើងនៃជំពូកទាំងដប់ប្រាំនេះហៅថា ទំនុកចម្រៀងតាមថ្នាក់។ តើហេតុអ្វីបានជាគេហៅថាជាទំនុកចម្រៀងតាមថ្នាក់? បណ្ឌិត ម៉ាទីន-លូធ័រ ហៅជំពូកទាំង១៥នេះថា ជាកាំឡើងថ្នាក់ខ្ពស់ជាង។ អ្នកប្រាជ្ញព្រះគម្ពីរជាតិហេព្រើរមួយរូបបានអោយចំណងថា "ដំណើរត្រឡប់ទៅផ្ទះវិញ"។ កន្សោមជំពូកទាំងដប់ប្រាំនេះត្រូវគេហៅថា ទំនុកចម្រៀងតាមថ្នាក់ ទំនងជាមានមូលហេតុពីរយ៉ាង។ ម្យ៉ាងនៅពេលដែលសាសន៍អ៊ីស្រាអែល ត្រឡប់ពីធ្វើជាឈ្លើយនៅប្រទេសបាប៊ីឡូនវិញ គេចំណាយពេលអស់រយៈពេលប្រាំខែ ទើបធ្វើដំណើរដល់ទីក្រុងយេរូសាឡិម។ គម្ពីរអែសរ៉ា៧:៩ចែងថា "ដ្បិតលោកបានចេញពីក្រុងបាប៊ីឡូននៅថ្ងៃ១ខែចេត្រ ក៏មកដល់ក្រុងយេរូសាឡិមនៅថ្ងៃ១ខែស្រាពណ៍..." ខ៩បរិយាយពីសាសន៍អ៊ីស្រាអែលធ្វើដំណើរឡើងមកទីក្រុងយេរូសាឡិម ក្រោមការដឹកនាំរបស់សង្ឃអែសរ៉ា។ ពេលធ្វើដំណើរជិតមកដល់ទីក្រុងយេរូសាឡិម គេមានសេចក្តីសប្បាយរីករាយ និងភាពទុទ្ថិដ្ឋិនិយមមានកាន់តែខ្លាំងឡើងៗ។ ម្យ៉ាងទៀត កន្សោមជំពូកទាំងដប់ប្រាំនេះហៅថា ទំនុកចម្រៀង

តាមថ្នាក់ ពីព្រោះនៅក្នុងក្រឹត្យវិន័យរបស់លោកម៉ូសេ ព្រះជាម្ចាស់បង្គាប់អោយពួកប្រុសៗក្នុងចំណោមសាសន៍អ៊ីស្រាអែល ត្រូវឡើងទៅទីក្រុងយេរូសាឡិមក្នុងមួយឆ្នាំបីដង ដើម្បីថ្វាយបង្គំដល់ព្រះជាម្ចាស់។ នៅពេលនោះពួកប្រុសៗនាំប្រពន្ធកូនរបស់គេទៅជាមួយផងដែរ។ ពេលគេធ្វើដំណើរកាន់តែជិតដល់ទីក្រុងយេរូសាឡិម សេចក្តីរីករាយ និងសេចក្តីរំភើបរបស់គេ បានឡើងតាមថ្នាក់ដែរ។ គេធ្វើដំណើរបណ្តើរ គេច្រៀងបទទំនុកដំកើងទាំងដប់ប្រាំជំពូកនេះបណ្តើរ។ ពេលគេចេញដំណើរ ប្រហែលជាគេច្រៀងគម្ពីរទំនុកដំកើងជំពូក១២០ ១២១ ១២២ជាបន្តបន្ទាប់។ លុះគេធ្វើដំណើរទៅដល់មាត់ទ្វារព្រះវិហារទីក្រុងយេរូសាឡិម គេនាំគ្នាច្រៀងគម្ពីរទំនុកដំកើងជំពូក១៣៤។

បទពិសោធន៍ដូចខ្ញុំបានជម្រាបជូនខាងលើ បណ្ឌិតលូកាបានកត់ត្រាទុកដំណើរពនេចររបស់រាស្ត្រព្រះអង្គ ឆ្ពោះទៅកាន់ទីក្រុងយេរូសាឡិមក្នុងគម្ពីរលូកា២:៤១-៥០។ នៅចន្លោះរយៈពេលដែលព្រះអម្ចាស់យេស៊ូវគ្រីស្ទប្រសូត រហូតដល់គ្រាដែលព្រះអង្គចាប់ផ្តើមបំពេញកិច្ចការព្រះអង្គ មានរយៈពេលសាមសិបឆ្នាំ។ ក្នុងអំឡុងពេលនោះ កាលទ្រង់មានព្រះជន្មាយុដប់ពីរព្រះវស្សា ព្រះអម្ចាស់យេស៊ូវគ្រីស្ទយាងទៅទីក្រុងយេរូសាឡិមជាមួយនឹងឪពុកម្តាយរបស់ទ្រង់ ដើម្បីទៅចូលរួមអបអរសាទរក្នុងពិធីបុណ្យណាមួយក្នុងចំណោមបុណ្យទាំងបី។ តាមទំនៀមទម្លាប់របស់សាសន៍អ៊ីស្រាអែល ពេលគេធ្វើដំណើរទៅចូលរួមធ្វើពិធីបុណ្យទាំងបីនោះ គេត្រូវនាំគ្នាឈប់សម្រាកនៅភូមិមួយ ចម្ងាយប្រមាណដើរអស់មួយថ្ងៃពីទីក្រុងយេរូសាឡិម។ អ្នកដំណើរពីគ្រប់ខេត្តគ្រប់ស្រុក ត្រូវប្រជុំគ្នានៅកន្លែងនោះ រួចហើយគេធ្វើដំណើរជាក្បួនដើម្បីចូលទីក្រុង

យេរូសាឡិម។ នៅពេលគេហែក្បួននោះ គេច្រៀងទំនុកចម្រៀងតាមថ្នាក់ពីជំពូក ១២០-១៣៤។ សេចក្តីបរិយាយខាងលើ មានភស្តុតាងបញ្ជាក់យ៉ាងពិត។ គម្ពីរទំនុកដំកើងជំពូក១២២:៣-៤ចែងថា "យេរូសាឡិមអើយ ឯងបានសង់ឡើង ដូចជាទីក្រុងដែលណែនណាន់ជាប់គ្នា ជាកន្លែងដែលអស់ទាំងពូជអំបូរ គឺជាពូជអំបូរនៃព្រះយេហូវ៉ា គេឡើងទៅតាមទំលាប់នៃសាសន៍អ៊ីស្រាអែល ដើម្បីនឹងអរព្រះគុណដល់ព្រះនាមព្រះយេហូវ៉ា"។ ជារៀងរាល់ឆ្នាំ ព្រះជាម្ចាស់បង្គាប់អោយសាសន៍អ៊ីស្រាអែល ត្រូវឡើងទៅទីក្រុងយេរូសាឡិមដើម្បីធ្វើពិធីបុណ្យបីយ៉ាង បុណ្យទីមួយគឺបុណ្យរំលង បុណ្យទីពីរគឺបុណ្យថ្ងៃទីហាសិប បុណ្យទីបីគឺបុណ្យបារាំ។ ក្នុងពិធីបុណ្យទាំងបីនេះ គេអរគុណដល់ព្រះជាម្ចាស់ គេថ្វាយបង្គំទ្រង់ និងថ្វាយយញ្ញបូជាតាមក្រឹត្យវិន័យតម្រូវ។

ទំនុកច្រៀងតាមថ្នាក់ដែលមាននៅក្នុងកន្សោមជំពូកទាំងដប់ប្រាំ មានអត្ថប្រយោជន៍ខាងព្រលឹងវិញ្ញាណសម្រាប់យើងយកមកអនុវត្ត។ ជីវិតគ្រីស្ទបរិស័ទ ត្រូវឈានឡើងពីមួយកាំទៅមួយកាំជារៀងរាល់ថ្ងៃ។ ក្នុងកាំទីមួយយើងចូលមកចំពោះព្រះជាម្ចាស់សារភាពថា យើងជាមនុស្សមានបាប។ យើងត្រូវទទួលស្គាល់ថា យើងរស់នៅដាច់ឆ្ងាយពីព្រះអង្គ ទាំងគ្មានមធ្យោបាយណាដើម្បីភ្ជាប់ខ្លួនយើងជាមួយនឹងទ្រង់។ ពេលនោះយើងយល់ព្រមទទួលយកសេចក្តីសង្គ្រោះ ដែលព្រះអម្ចាស់ប្រទានដល់យើងតាមរយៈសេចក្តីសុគត និងការរស់ឡើងវិញនៃព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ចាប់ពីពេលនោះទៅ ព្រះអង្គបានហៅយើងថា ជាអ្នកសុចរិតនៅចំពោះព្រះអង្គ។ ព្រះអង្គប្រទានអោយព្រះវិញ្ញាណបរិសុទ្ធមកគង់ក្នុងជីវិតរបស់យើង ដើម្បីញែកយើងអោយបានបរិសុទ្ធ

ក្នុងពេលដែលយើងកំពុងតែមានការធំធាត់ខាងព្រលឹងវិញ្ញាណ ព្រមទាំងមានការដុះលូតលាស់ក្នុងព្រះគុណ ដោយសារយើងបានស្គាល់អង្គព្រះយេស៊ូវគ្រីស្ទ។ ជីវិតគ្រីស្ទបរិស័ទត្រូវលូតលាស់ឈានឡើងដល់ថ្នាក់ខ្ពស់ជាងម្តងមួយកាំៗ។ ឯការលូតលាស់ខាងព្រលឹងវិញ្ញាណរបស់យើង ក៏ត្រូវលូតលាស់ឆ្ពោះទៅខាងភាពសុចរិតជាបន្តបន្ទាប់ដែរ។ បើលោកអ្នកពិតជាមានជំនឿលើព្រះអម្ចាស់យេស៊ូវមែន ជីវិតរបស់លោកអ្នកមិនរស់នៅតែទាបរហូតទេ។ ឆ្នាំនេះ លោកអ្នកបានឡើងថ្នាក់ខ្ពស់ជាងឆ្នាំមុន។ បើយើងមិនឃើញខ្លួនយើងថា មានការលូតលាស់ដល់ថ្នាក់ខ្ពស់ជាងខាងសេចក្តីសុចរិតទេ លោកអ្នកជាគ្រីស្ទបរិស័ទកើតរោគក្រិនហើយ។

សូមអញ្ជើញលោកអ្នកចូលរួមដំណើរពនេចរជាមួយនឹងសិក្ខាកាម ដោយផ្តើមរៀនទំនុកច្រៀងតាមថ្នាក់ពីជំពូក១២០នេះតទៅ។ ពេលលោកអ្នកធ្វើដំណើរ លោកអ្នកជាជនពនេចរហើយ។ ជនពនេចរមានទិសដៅជាក់លាក់ ឯទិសដៅនោះ គឺដំណាក់របស់ព្រះយេហូវ៉ានៅឯស្ថានសួគ៌។

**១កាលខ្ញុំមានសេចក្តីវេទនា នោះបានអំពាវនាវដល់ព្រះយេហូវ៉ា**
**ហើយទ្រង់បានតបមកខ្ញុំ ២ឱព្រះយេហូវ៉ាអើយ សូមជួយព្រលឹង**
**ទូលបង្គំ ឲ្យរួចពីបបូរមាត់ដ៏កំភូត ហើយពីអណ្តាតដែលបញ្ឆោត**
**៣ឱអណ្តាតដែលបញ្ឆោតអើយ តើត្រូវឲ្យអ្វីដល់ឯង តើត្រូវធ្វើអ្វី**
**ទៀតដល់ឯង ៤គឺព្រួញមុតរបស់មនុស្សខ្លាំងពូកែ នឹងរងើកភ្លើង**

**ឈើដង្កោផង ៥វេទនាដល់ខ្ញុំ ព្រោះអាស្រ័យនៅស្រុកមែសេក**
**គឺដែលខ្ញុំនៅកណ្ដាលត្រសាលនៃសាសន៍កេដារ ៦ជាយូរមកហើយ**
**ព្រលឹងនៃខ្ញុំបាននៅជាមួយនឹងពួកអ្នកដែលស្អប់សេចក្ដីសុខ ៧ខ្ញុំ**
**ចូលចិត្តខាងសេចក្ដីសុខ តែកាលណាខ្ញុំថាទៅ នោះគេចូលចិត្តតែ**
**ចង់ច្បាំងវិញ (ទំនុដំកើង១២០:១-៧)។**

បទគម្ពីរនេះស៊ីសង្វាក់នឹងស្ថានការណ៍ ដែលកំពុងតែកើតឡើងក្នុងលោកយើងនាពេលបច្ចុប្បន្ននេះ ពិសេសចំពោះសាសន៍អ៊ីស្រាអែល។ ខ៥សម្ដែងថា "វេទនាដល់ខ្ញុំ ព្រោះអាស្រ័យនៅស្រុកមែសេក គឺដែលខ្ញុំនៅកណ្ដាលត្រសាលនៃសាសន៍កេដារ"។ តើសាសន៍មែសេក គឺជាសាសន៍ណា? នៅក្នុងគម្ពីរលោកុប្បត្តិ១០:២បានចែងថា "ឯកូនរបស់យ៉ាផែតគឺកូមើរ ម៉ាកុក ម៉ាដាយ យ៉ាវ៉ាន ទូបាល មែសេក នឹងទីរ៉ាស"។ សាសន៍មែសេកជាកូនចៅរបស់លោកយ៉ាផែត។ យើងជាសាសន៍ដទៃភាគច្រើន ជាពូជពង្សរបស់លោកយ៉ាផែត។ សាសន៍អ៊ីស្រាអែលជាពូជពង្សរបស់លោកសិម ជាកូនប្រុសមួយរូបរបស់លោកណូអេ។ បច្ចុប្បន្ន យើងឃើញថាសាសន៍អ៊ីស្រាអែលតាំងទីលំនៅចំកណ្ដាលចំណោមសាសន៍ដទៃ។ នគរអ៊ីស្រាអែលសព្វថ្ងៃស្ថិតរស់នៅក្នុងចំណោមពូជពង្សរបស់លោកអ៊ីស្មាអែល ដែលត្រូវជាកូនចុងរបស់លោកតាអ័ប្រាហាំ។ តើសាសន៍អ៊ីស្មាអែលបច្ចុប្បន្ននេះជាសាសន៍ណា? សាសន៍អ៊ីស្មាអែលសព្វថ្ងៃនេះ គឺជាប្រជាពលរដ្ឋអារ៉ាប់។ តើខគម្ពីរខាងលើសម្ដែងត្រឹមត្រូវដែរឬទេថា នគរ

អ៊ីស្រាអែលបច្ចុប្បន្នកំពុងរស់នៅកណ្ដាលចំណោមប្រជាពលរដ្ឋអារ៉ាប់? ខគម្ពីរដែលយើងសិក្សានៅថ្ងៃនេះស៊ីសង្វាក់ជាមួយនឹងសាសន៍អ៊ីស្រាអែលបច្ចុប្បន្ន។

ខ២សម្ដែងថា "ឱព្រះយេហូវ៉ាអើយ សូមជួយព្រលឹងទូលបង្គំឱ្យរួចពីបបូរមាត់ដ៏កំភូត ហើយពីអណ្ដាតដែលបញ្ឆោត"។ តាមការសង្កេត ពលរដ្ឋដែលរស់នៅជុំវិញសាសន៍អ៊ីស្រាអែលមានចិត្តមិនល្អចំពោះសាសន៍នេះទេ។ គម្ពីរចែងថា សាសន៍អ៊ីស្រាអែលរស់នៅកណ្ដាលបណ្ដាជនដែលមាន "អណ្ដាតបញ្ឆោត"។ តើប្រជាពលរដ្ឋអារ៉ាប់និយាយល្អពីសាសន៍អ៊ីស្រាអែលដែរឬទេ? កាលខ្ញុំសិក្សានៅសាលាព្រះគម្ពីរមានសាសន៍អារ៉ាប់ម្នាក់រៀនជាមួយនឹងខ្ញុំដែរ។ ខ្ញុំសួរសិស្សម្នាក់នោះពីដំណើរសាសន៍អ៊ីស្រាអែល គាត់ឆ្លើយមកខ្ញុំដោយគំរោះគំរើយថា "នៅលើលោកនេះគ្មានសាសន៍អ៊ីស្រាអែលទេ"។ នៅក្នុងពត៌មានប្រចាំថ្ងៃ យើងឃើញមានការប្រឆាំងគ្នារវាងសាសន៍អារ៉ាប់ និងសាសន៍អ៊ីស្រាអែលដែរ។ សាសន៍អារ៉ាប់មិនដែលនិយាយល្អពីសាសន៍អ៊ីស្រាអែលទេ។ ការនិយាយប្រឆាំងនឹងពូជពង្សរបស់លោកសិម ប្រព្រឹត្តទៅអស់រយៈពេលរាប់ពាន់ឆ្នាំកន្លងមកហើយ។ ប៉ុន្តែ ទោះបីជាជនភាគតិចនៅសាសន៍អារ៉ាប់ មិនអាចបំផ្លាញសាសន៍អ៊ីស្រាអែល ដោយប្រការណាឡើយ។ ចំណុចនេះបញ្ជាក់អោយយើងដឹងថា ព្រះជាម្ចាស់មិនទាន់អស់ចិត្តជាមួយសាសន៍អ៊ីស្រាអែលនៅឡើយទេ។ ព្រះអង្គនៅតែរក្សាសាសន៍នេះអោយមានជានិច្ចរហូតដល់គ្រាមួយពាន់ឆ្នាំ។ គ្រានោះព្រះអម្ចាស់យាងមកសោយរាជ្យនៅលើផែនដី។ ខ៧សម្ដែងថា "ខ្ញុំចូលចិត្តខាងសេចក្ដីសុខ តែកាលណាខ្ញុំថាទៅ នោះគេចូលចិត្តតែចង់ច្បាំងវិញ"។

សាសន៍អ៊ីស្រាអែល និងសាសន៍អារ៉ាប់មិនគ្រាន់តែឪដងដាក់គ្នាដោយប្រើពាក្យសម្ដីតែម៉្យាងប៉ុណ្ណោះទេ។ គេចូលចិត្តប្រើអំពើហិង្សា ដោយប្រើអាវុធធ្វើសង្គ្រាមរវាងជាតិសាសន៍ទាំងពីរនេះថែមទៀតផង។ តើលោកអ្នកឮថាមានសេចក្ដីសុខកើតឡើងនៅទីក្រុងយេរូសាឡិមដែរឬទេ? បច្ចុប្បន្ននេះ ទីក្រុងយេរូសាឡិមមិនមានសេចក្ដីសុខទេ។

ប៉ុន្តែ ទោះបីទីក្រុងយេរូសាឡិមមិនមានសេចក្ដីសុខក៏ដោយ សាសន៍អ៊ីស្រាអែលនាំគ្នាធ្វើដំណើរទៅទីក្រុងនេះ។ គេចាកចេញពីមែសេក ចាកចេញពីកេដារធ្វើដំណើរឆ្ពោះទៅទីក្រុងយេរូសាឡិម ដើម្បីថ្វាយបង្គំដល់ព្រះជាម្ចាស់។ យេរូសាឡិមប្រែថា ទីក្រុងនៃសេចក្ដីសុខសាន្ត។ ប៉ុន្តែ បើតាមដំណឹងក្នុងពត៌មានសព្វថ្ងៃ យេរូសាឡិមគ្មានសេចក្ដីសុខសាន្តទេ។ គ្រាអនាគតខាងមុខទៀត ទើបទីក្រុងយេរូសាឡិមជាទីក្រុងនៃសេចក្ដីសុខសាន្ត។

# ជំពូក ១២១

***ចាចចនា*** *ជនពនេចរមើលឃើញកំពូលភ្នំយូដា*

ជំពូក១២១ ស្ថិតនៅក្នុងចង្កោមជំពូកទាំងដប់ប្រាំ ដែលបរិយាយពីទំនុកច្រៀងតាមថ្នាក់។ ជំពូក១២០ជាចំណុចចាប់ផ្តើមនៃការធ្វើដំណើរឆ្ពោះទៅកាន់ទីក្រុងយេរូ-សាឡិម។ ជំពូក១២១ ជាក្បួនព្យុះហយាត្រាដែលអ្នកដង្ហែរក្បួនសម្លឹងមើលឃើញកំពូលភ្នំស្រុកយូដា។ ទីក្រុងយេរូសាឡិមសង់នៅចន្លោះភ្នំនោះ។ នៅពេលសាសន៍អ៊ីស្រាអែលឃើញកំពូលភ្នំ គេមានសេចក្តីរីករាយកាន់តែខ្លាំង។

**ខ្ញុំនឹងងើបភ្នែកមើលទៅឯភ្នំ តែសេចក្តីជំនួយជួយដល់ខ្ញុំមកពីណា (ទំនុកដំកើង១២១:១)។**

ខ១ជាសំណួរសួរថា "ខ្ញុំងើបភ្នែកមើលទៅឯភ្នំ តើជំនួយរបស់ខ្ញុំមកពីភ្នំនោះឬ? ភ្នំនោះមិនអាចជួយដល់សាសន៍អ៊ីស្រាអែលបានទេ។ ចម្លើយនៃសំណួរនេះគឺ :

**សេចក្តីជំនួយរបស់ខ្ញុំមកតែពីព្រះយេហូវ៉ាទេ គឺជាព្រះដែលបង្កើត**

**ផ្ទៃមេឃ នឹងផែនដី (ទំនុកដំកើង១២១:២)។**

ជំនួយសម្រាប់សាសន៍អ៊ីស្រាអែលមកពីព្រះយេហូវ៉ា ជាព្រះដែលបង្កើតផ្ទៃមេឃនិងផែនដី។

នៅពេលសាសន៍អ៊ីស្រាអែលធ្វើដំណើរឆ្ពោះទៅកាន់ទីក្រុងយេរូសាឡិម ពីទិសខាងកើត ខាងលិច ខាងជើង ខាងត្បូង គេចាំបាច់ត្រូវធ្វើដំណើរឆ្លងជងភ្នំព័ទ្ធជុំវិញទីក្រុងយេរូសាឡិម។ ទោះមកពីទិសណាក្តី គេត្រូវឆ្លងខ្នងភ្នំនោះជាចាំបាច់។

នៅលើខ្នងភ្នំដែលហ៊ុមព័ទ្ធទីក្រុងយេរូសាឡិម មានអាសនាថ្វាយបង្គំរូបព្រះដែលសាសន៍ដទៃបានសង់នៅទីនោះ។ ដូចច្នេះ បានជារាស្ត្ររបស់ព្រះអង្គសួរថា "ខ្ញុំងើបភ្នែកមើលទៅឯភ្នំ តើជំនួយរបស់ខ្ញុំមកពីណា?" ជំនួយមិនមកពីភ្នំនោះទេ ដ្បិតនៅលើកំពូលភ្នំនោះ ជាកន្លែងដែលគេសង់ព្រះវិហារថ្វាយបង្គំរូបព្រះ។ លោកយេរេមាបង្ហើបអោយយើងដឹងពីដំណើរនេះដែរថា "ការដែលទុកចិត្តសង្ឃឹមដល់ភ្នំតូច ហើយដល់ពួកអឹកធឹកនៅលើភ្នំធំ នោះពិតប្រាកដជាឥតប្រយោជន៍ទទេ សេចក្តីសង្គ្រោះនៃសាសន៍អ៊ីស្រាអែល នោះស្រេចនឹងព្រះយេហូវ៉ា ជាព្រះនៃយើងជាពិតវិញ"(យេរេមា ៣:២៣)។ ចម្រៀងនេះ ពួកសាសន៍អ៊ីស្រាអែលច្រៀងរួមគ្នា ពេលគេធ្វើដំណើរជិតដល់ទីក្រុងយេរូសាឡិម។

**៣ "ទ្រង់នឹងមិនឱ្យជើងអ្នករអិលភ្លាត់ឡើយ ព្រះអង្គដែលរក្សាអ្នក**

**ទ្រង់នឹងមិនផ្ទំរលីវឡើយ [៤]មើល ព្រះអង្គដែលរក្សាអ៊ីស្រាអែល ទ្រង់នឹងមិនដែលងោកងុយ ក៏មិនដែលផ្ទំលក់ឡើយ (ទំនុកដំកើង ១២១:៣-៤)។**

“ទ្រង់នឹងមិនឱ្យជើងអ្នករឥលភ្លាត់ឡើយ...” ចំណុចនេះមានន័យថា ព្រះជាម្ចាស់មិនដែលបណ្តោយអោយជើងយើងរឥលភ្លាត់ឡើយ បើយើងពឹងពាក់លើព្រះអង្គគ្រប់ដង្ហើមចេញចូល។ ព្រះបន្ទូលសន្យានេះ មិនមែនជារឿងប្រឌិតទេ គឺជារឿងពិត។ បើលោកអ្នកពឹងពាក់លើព្រះជាម្ចាស់រៀងរាល់ដង្ហើមចេញចូលរបស់លោកអ្នក ជើងរបស់លោកអ្នកពិតជាមិនរឥលភ្លាត់ធ្លាក់ទៅក្នុងអំពើបាបឡើយ។

**[៦]នៅពេលថ្ងៃអ្នកនឹងមិនត្រូវព្រះអាទិត្យធ្វើទុក្ខឡើយ ហើយនៅពេលយប់ក៏មិនត្រូវព្រះចន្ទធ្វើទុក្ខដែរ [៧]ព្រះយេហូវ៉ានឹងរក្សាអ្នកឱ្យរួចពីគ្រប់ទាំងសេចក្តីអាក្រក់ ទ្រង់នឹងថែរក្សាព្រលឹងរបស់អ្នក [៨]ឯដំណើរដែលអ្នកចេញចូលទៅមក នោះព្រះយេហូវ៉ាទ្រង់នឹងរក្សា ចាប់តាំងពីឥឡូវនេះរៀងតទៅ (ទំនុកដំកើង១២១:៦-៨)។**

សាសន៍អ៊ីស្រាអែលដែលដើរជាក្បួនសំដៅទៅទីក្រុងយេរូសាឡិម មិនបានមើលទៅភ្នំដើម្បីសូមកម្លាំងទេ។ គេសម្លឹងភ្នែកទៅចំព្រះយេហូវ៉ាអោយទ្រង់ជួយដល់

គេ។ ព្រះយេហូវ៉ាទ្រង់ជាអ្នកថែរក្សាដល់រាស្ត្ររបស់ទ្រង់។

ខ៧-៨សម្តែងថា "ព្រះយេហូវ៉ាថានឹងរក្សាអ្នក ឱ្យរួចពីគ្រប់ទាំងសេចក្តីអាក្រក់ ទ្រង់នឹងថែរក្សាព្រលឹងរបស់អ្នក... ចាប់តាំងពីឥឡូវរៀងតទៅ"។ បើយើងទុកចិត្តដល់សេចក្តីសន្យាដែលព្រះជាម្ចាស់មានបន្ទូលនៅក្នុងខនេះ ព្រះអង្គមានគ្រប់ចេស្តាដើម្បីរក្សាព្រលឹងយើង ចាប់តាំងពីពេលដែលយើងអំពាវនាវហៅរកព្រះអង្គនេះតរៀងទៅ។ គម្ពីរ១ពេត្រុស១:៥ ចែងដូច្នេះដែរថា "ឱ្យយើងរាល់គ្នា ដែលព្រះចេស្តានៃព្រះកំពុងតែថែរក្សា ដោយសារសេចក្តីជំនឿ សំរាប់ឱ្យបានសេចក្តីសង្គ្រោះដែលប្រុងប្រៀបនឹងសំដែងមកនៅជាន់ក្រោយបង្អស់នោះ"។ ព្រះយេហូវ៉ាទ្រង់ថែរក្សាព្រលឹងរាស្ត្ររបស់ទ្រង់។ មនុស្សយើងអាចទុកផ្លែឈើបានយូរ ដោយប្រើមធ្យោបាយពីរយ៉ាង។ម្យ៉ាងយើងប្រើស្ករធ្វើជាដំណាប់។ ម្យ៉ាងទៀត យើងយកផ្លែឈើទៅត្រាំនឹងទឹកខ្មេះ។ គ្រីស្ទបរិស័ទភាគច្រើនរក្សាព្រលឹងខ្លួនមិនអោយខូច ខ្លះដោយប្រើស្ករ ខ្លះប្រើទឹកខ្មេះ។ គ្រីស្ទបរិស័ទណាដែលប្រើស្ករ គ្រីស្ទបរិស័ទនោះមានរសជាតិផ្អែមល្ហែម។ ចំណែកគ្រីស្ទបរិស័ទណាដែលយកព្រលឹងរបស់ខ្លួនទៅត្រាំក្នុងទឹកខ្មេះ គ្រីស្ទបរិស័ទរូបនោះមានជាតិជូរ អាចយកមកជ្រក់ត្រីក៏បានដែរ។

នៅពេលសាសន៍អ៊ីស្រាអែល នាំគ្នាធ្វើដំណើរជាក្បួនយ៉ាងធំឆ្ពោះទៅទីក្រុងយេរូសាឡិម ភ្នែកគេសម្លឹងទៅឯព្រះយេហូវ៉ា ដែលទ្រង់ជាអ្នកថែរក្សាគេ។ ឯព្រះយេហូវ៉ាវិញ ទ្រង់ថែរក្សាព្រលឹងរបស់គេទាំងចេញទាំងចូល។ ទ្រង់រក្សាគេចាប់តាំងពីឥឡូវនេះតរៀងទៅ។ សេចក្តីសន្យានេះ មានទម្ងន់ខ្លាំងណាស់ សម្រាប់ព្រលឹងអ្នកជឿ

ព្រះអង្គគ្រប់៧រូប។ នៅក្នុងព្រះគម្ពីរមានសេចក្តីសន្យា ប្រភេទនេះជាច្រើនកន្លែង។ គម្ពីរសុភាសិត៣:២៦ចែងថា "ដ្បិតព្រះយេហូវ៉ាទ្រង់នឹង បានជាទីទុកចិត្តដល់ឯង ទ្រង់នឹងរក្សាជើងឯងមិនឱ្យត្រូវជាប់ឡើយ"។ បើយើងទុកចិត្តលើព្រះអង្គ ទ្រង់មិនបណ្តោយអោយយើងធ្លាក់ទេ។ គម្ពីរទំនុកដំកើង៣៧:២៤ចែងថា "ទោះបើគេភ្លាត់ដួល គង់តែមិនត្រូវដួលទាំងស្រុងទេ ដ្បិតព្រះយេហូវ៉ាទ្រង់ទ្រអ្នកនោះដោយព្រះហស្ត"។ គម្ពីរ១សាំយ៉ូអែល២:៩នាងហាណាអះអាងថា "ទ្រង់នឹងគាំពារជើងនៃពួកអ្នកបរិសុទ្ធរបស់ទ្រង់ តែពួកអាក្រក់នឹងត្រូវស្ងៀមស្ងាត់នៅក្នុងទីងងឹតវិញ ដ្បិតមនុស្សមិនមែនឈ្នះដោយនូវកំឡាំងបានទេ"។ ចំណែកគម្ពីរយូដាស១២៤-២៥ព្រះជាម្ចាស់សន្យាថានឹងរក្សាដល់រាស្ត្រទ្រង់ដូច្នេះថា "រីឯព្រះ ដែលអាចនឹងថែរក្សា មិនឱ្យអ្នករាល់គ្នាជំពប់ដួល ហើយនឹងដាក់អ្នករាល់គ្នា នៅចំពោះសិរីល្អទ្រង់ ដោយឥតមានកន្លែងបន្ទោសបាន ព្រមទាំងមានចិត្តត្រេកអរផង គឺជាព្រះអង្គដ៏ជាព្រះតែមួយ ជាព្រះអង្គសង្គ្រោះនៃយើងរាល់គ្នា ដោយសារព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងនោះសូមឱ្យទ្រង់បានសិរីល្អ ឫទ្ធានុភាព ព្រះចេស្តា នឹងអំណាច តាំងពីមុនអស់កល្បនៅជាន់ឥឡូវនេះ ហើយទៅដល់អស់កល្បជានិច្ចតទៅអាម៉ែន"។ ព្រះជាម្ចាស់មានចេស្តាយ៉ាពោរពេញ អាចរក្សាយើងដែលទុកចិត្តដល់ព្រះអង្គ។ ព្រះអង្គរក្សាសាសន៍អ៊ីស្រាអែល ក៏ដូចរក្សាដល់រាស្ត្ររបស់ទ្រង់ដែលកោតខ្លាច នឹងមានសេចក្តីសង្ឃឹមដល់សេចក្តីសប្បុរសរបស់ទ្រង់។

ម្យ៉ាងវិញទៀត ព្រះបន្ទូលនៅក្នុងខ៦សន្យាថា "នៅពេលថ្ងៃអ្នកនឹងមិនត្រូវព្រះអាទិត្យធ្វើទុក្ខឡើយ ហើយនៅពេលយប់ក៏មិនត្រូវព្រះចន្ទធ្វើទុក្ខដែរ"។ ព្រះជាម្ចាស់

អាចថែរក្សាយើង ពីព្រោះព្រះអង្គមិនដែលងុយងោកម្ដងណាទេ។ ព្រះអង្គទតមើលអ្នកកោតខ្លាចដល់ព្រះអង្គរៀងរាល់វិនាទី។ ទោះបីយប់ដែលមានពន្លឺព្រះចន្ទយ៉ាងភ្លឺថ្លា ឬយប់ងងឹតជាក់ភ្នែកមិនយល់ ព្រះជាម្ចាស់ថែរក្សាយើង។ ខ៨ចែងថា "ឯដំណើរដែលអ្នកចេញចូលទៅមក នោះព្រះយេហូវ៉ាទ្រង់នឹងរក្សាចាប់តាំងពីឥឡូវនេះរៀងតទៅ"។ យើងមានសុវត្ថិភាពយ៉ាងបរិបូរ បើយើងទុកចិត្តដល់ព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់។

# ជំពូក ១២២

***ធាតុចនា*** *ជនពនេចររំកិលជិតដល់ក្រុងយេរូសាឡិម*

ជំពូក១២២ ជាជំពូកដែលស្ថិតនៅក្នុងចង្កោមទំនុកចម្រៀងតាមថ្នាក់ដែរ។ ជំពូក១២០ជាកិច្ចចាប់ផ្ដើម។ ជំពូក១២១ រាស្ត្រព្រះអង្គសម្លឹងមើលឃើញខ្នងភ្នំ ដែលព័ទ្ធជុំវិញទីក្រុងយេរូសាឡិម។ ជំពូក១២២ ជាដំណើរសាសន៍អ៊ីស្រាអែលចូលដល់ទីក្រុងយេរូសាឡិម។

> **១ កាលគេនិយាយមកខ្ញុំថា ចូរយើងចូលទៅក្នុងដំណាក់នៃព្រះ**
> **យេហូវ៉ា នោះខ្ញុំមានសេចក្ដីអំណរអរណាស់ ២ ឱក្រុង**
> **យេរូសាឡិមអើយ ជើងយើងឈរនៅខាងក្នុងទ្វាររបស់ឯងហើយ**
> **៣ យេរូសាឡិមអើយ ឯងបានសង់ឡើង ដូចជាទីក្រុងដែលណែន**
> **ណាន់ជាប់គ្នា ៤ ជាកន្លែងដែលអស់ទាំងពូជអំបូរ គឺពូជអំបូរនៃព្រះ**
> **យេហូវ៉ា គេឡើងទៅតាមទំលាប់នៃសាសន៍អ៊ីស្រាអែល ដើម្បីនឹង**
> **អរព្រះគុណដល់ព្រះនាមព្រះយេហូវ៉ា (ទំនុកដំកើង១២២:១-៤)។**

ឥឡូវនេះ ក្បួនព្យុហយាត្រារបស់សាសន៍អ៊ីស្រាអែល បានចូលមកដល់ទីក្រុងយេរូសាឡិមហើយ។ ភ្នែកគេបានឃើញវិហារទីក្រុងយេរូសាឡិម។ ដូច្នេះហើយ បានជាគេនិយាយថា "...ចូរយើងចូលទៅក្នុងដំណាក់នៃព្រះយេហូវ៉ា..."។

ជំពូក១២២ សម្ដែងពីទឹកចិត្តរីករាយរបស់រាស្ត្រព្រះជាម្ចាស់ កាលគេធ្វើដំណើរមកដល់ដំណាក់ទ្រង់។ លើសពីនោះទៅទៀតជំពូក១២២ ជាបទទំនាយដែលត្រូវកើតឡើងក្នុងគ្រាអនាគត។ នៅពេលព្រះអម្ចាស់យេស៊ូវគ្រីស្ទយាងមកតាំងរាជ្យទ្រង់នៅលើផែនដីក្នុងគ្រាមួយពាន់ឆ្នាំ សាសន៍អ៊ីស្រាអែលត្រូវធ្វើដំណើរពីគ្រប់ទីកន្លែងនៅលើសកលលោក ត្រឡប់មកទីក្រុងយេរូសាឡិមថ្វាយបង្គំព្រះអង្គនៅទីនោះ។ ទីក្រុងយេរូសាឡិមក្នុងពេលនោះ មានលក្ខណៈមិនដូចជាទីក្រុងយេរូសាឡិមសព្វថ្ងៃនេះទេ។ ទីក្រុងយេរូសាឡិមនៃប្រទេសអ៊ីស្រាអែលបច្ចុប្បន្ន មានភាពច្របូកច្របល់ខ្លាំងណាស់។ នៅកន្លែងដែលព្រះវិហារស្ដេចសាឡូម៉ូនធ្លាប់សង់ សព្វថ្ងៃមានវិហារសាសនាអ៊ីស្លាមឈ្មោះអូម៉ាបានសង់នៅកន្លែងនោះជំនួសវិញ។ សាសន៍ដទៃកំពុងគ្រប់គ្រងទីលានបរិសុទ្ធរបស់សាសន៍អ៊ីស្រាអែលនៅទីក្រុងយេរូសាឡិម។ ដំណើរនេះគម្ពីរហូសេ៣:៤-៥ចែងថា "ពីព្រោះពួកកូនចៅអ៊ីស្រាអែលនឹងនៅឥតមានស្ដេច ឬចៅហ្វាយ ឥតការថ្វាយយញ្ញបូជា ឬបង្គោលគោរពឥតអេផូឌ ឬរូបព្រះ ជាយូរអង្វែង ក្រោយនោះ ពួកកូនចៅអ៊ីស្រាអែលនឹងវិលមកវិញ ហើយនឹងស្វែងរកព្រះយេហូវ៉ា ជាព្រះនៃគេ នឹងដាវីឌ ជាស្ដេចរបស់គេ នៅជាន់ក្រោយបង្អស់ គេនឹងមកពឹងជ្រកនឹងព្រះយេហូវ៉ា ហើយនឹងសេចក្ដីសប្បុរសនៃទ្រង់ ដោយញាប់ញ័រ"។

នៅគ្រាព្រះគ្រីស្ទសោយរាជ្យមួយពាន់ឆ្នាំ ទីក្រុងយេរូសាឡិមមានលក្ខណៈបរិសុទ្ធឥតមានអ្នកឯណាគ្រប់គ្រងនៅទីនោះ ដូចទីក្រុងយេរូសាឡិមបច្ចុប្បន្ននេះទេ។ តើទីក្រុងយេរូសាឡិមសម័យនោះមានលក្ខណៈបែបណា? អ្នកប្រាជ្ញគម្ពីរមួយរូបបណ្ឌិតហ្វែបឺរឡែនពណ៌នាពីទីក្រុងយេរូសាឡិមក្នុងគ្រាមួយពាន់ឆ្នាំថា “ទីក្រុងយេរូសាឡិមមានពន្លឺភ្លឺចែងចាំង សំណង់នីមួយៗស្អាតព្រមទាំងមានពណ៌ផ្លុះយ៉ាងចម្រុះថែមទៀតផង ផ្លូវថ្នល់ស្អាត គ្មានសម្រាម គ្មានធូលីអ្វីទាល់តែសោះ។ ចំណែកស្ថានភាពខាងព្រលឹងវិញ្ញាណរបស់អ្នកស្រុកដែលរស់នៅទីក្រុងយេរូសាឡិម មានចិត្តចង់តែថ្វាយបង្គំព្រះជាម្ចាស់រៀងរាល់ដង្ហើមចេញចូល។ នៅទីនោះមិនមានសង្គ្រាមទៀតទេ។ ជនណាដែលបង្កើតការអាក្រក់ ឬបង្កើតអោយមានបញ្ហា មិនអាចនៅក្នុងទីក្រុងយេរូសាឡិមក្នុងរាជ្យមួយពាន់ឆ្នាំនោះទៀតដែរ” *(បរិមាធិប្បាយកណ្ឌព្រះគម្ពីរទំនុកដំកើងទំព័រ ៤៤៧)*។ ទីក្រុងយេរូសាឡិមក្នុងរាជ្យមួយពាន់ឆ្នាំមានលក្ខណៈបរិសុទ្ធល្អប្រពៃ ទាំងទ្រង់ទ្រាយ ទាំងគំនិតរបស់អ្នកស្រុកដែលរស់នៅទីនោះ។ យើងឃើញរូបភាពដ៏ល្អត្រចះសម្រាប់ទីក្រុងដែលព្រះជាម្ចាស់ទ្រង់សង់ដោយព្រះហស្តទ្រង់ផ្ទាល់។

# ជំពូក ១២៣

***ចំណងជើង*** *ជនពនេចរធ្វើដំណើរទៅដល់ទីក្រុងយេរូសាឡិម*

ទំនុកដំកើងជំពូក១២៣ អាចអោយចំណងជើងថា "ភ្នែកបានឃើញដូចក្តីស្រមៃ"។ នៅពេលសាសន៍អ៊ីស្រាអែលបានឃើញដំណាក់ព្រះ ភ្នែករបស់គេមានពេញទៅដោយសេចក្តីសង្ឃឹម។ ដំណាក់ព្រះជាកន្លែងដែលគេជឿថា គេអាចចូលទៅជិតព្រះជាម្ចាស់បាន។

**ឱព្រះដែលគង់នៅស្ថានសួគ៌អើយ ទូលបង្គំងើបភ្នែកមើលដល់ទ្រង់ដោយសង្ឃឹម (ទំនុកដំកើង១២៣:១)។**

គម្ពីរនេះចែងថា "ឱព្រះដែលគង់នៅស្ថានសួគ៌អើយ..."។ សាសន៍អ៊ីស្រាអែលចង់បញ្ជាក់ថា ព្រះជាម្ចាស់មិនគង់នៅក្នុងវិហារដែលភ្នែកគេឃើញនោះទេ។ សាសន៍អ៊ីស្រាអែលជឿពិតប្រាកដថា គ្មាននរណាម្នាក់អាចយកព្រះមកដាក់ក្នុងប្រអប់បានឡើយ។ សាសន៍អ៊ីស្រាអែលសម្លឹងទៅស្ថានសួគ៌ សង្ឃឹមលើព្រះអង្គតែមួយប៉ុណ្ណោះ ដ្បិតព្រះអង្គទ្រង់ជាព្រះដែលគង់នៅស្ថានសួគ៌។ ពេលគេឃើញដំណាក់ទ្រង់គេសង្ឃឹម

ថា គេអាចទាក់ទងជាមួយនឹងព្រះជាម្ចាស់បាន ដ្បិតទ្រង់គង់នៅស្ថានសួគ៌។

**មើល ភ្នែកពួកទាសាក្រឡេកមើលទៅដៃចៅហ្វាយខ្លួន ហើយភ្នែក នៃទាសីក្រឡេកមើលទៅដៃចៅហ្វាយស្រីរបស់ខ្លួនយ៉ាងណា នោះភ្នែកយើងខ្ញុំក៏ក្រឡេកមើលទៅព្រះយេហូវ៉ា ជាព្រះនៃយើងខ្ញុំយ៉ាងនោះដែរ ទំរាំតែទ្រង់ផ្តល់សេចក្តីមេត្តាករុណាដល់យើងខ្ញុំ (ទំនុកដំកើង១២៣:២)។**

ដូចភ្នែករបស់ឈ្នួលបម្រើមើលទៅចៅហ្វាយរបស់ខ្លួនដោយសង្ឃឹម ភ្នែករបស់រាស្ត្រព្រះអង្គសម្លឹងមើលទៅព្រះជាម្ចាស់ដោយទីសង្ឃឹម នៅក្នុងជីវិតរបស់ខ្លួនយ៉ាងដូច្នោះដែរ។ ចំណែកព្រះអង្គ ទ្រង់ឃ្លាំមើលយើងរៀងរាល់ដង្ហើមចេញចូល។ ដូច្នេះ បើលោកអ្នកកំពុងឆ្លងកាត់ទុក្ខលំបាកដោយប្រការណា កុំអោយយល់ច្រឡំថា ព្រះជាម្ចាស់ដកព្រះនេត្រទ្រង់ចេញពីលោកអ្នកឡើយ។

**ឱព្រះយេហូវ៉ាអើយ សូមទ្រង់មេត្តាប្រោសដល់យើងខ្ញុំ សូមមេត្តាប្រោសយើងខ្ញុំផង ដ្បិតយើងខ្ញុំឆ្អែតចំពោះ សេចក្តីមើលងាយយ៉ាងក្រៃលែង (ទំនុកដំកើង១២៣:៣)។**

សាសន៍ដទៃមើលងាយដល់សាសន៍អ៊ីស្រាអែល។ ចំណែកសាសន៍អ៊ីស្រាអែលវិញចូលទៅឯដំណាក់ព្រះជាម្ចាស់ ដើម្បីសូមសេចក្តីមេត្តាករុណាពីទ្រង់។ គេធ្វើដំណើរទៅដំណាក់ព្រះ ដើម្បីអោយព្រះអម្ចាស់ទ្រង់រៀបចំដំណើរជីវិតរបស់គេត្រឹមត្រូវតាមផ្លូវរបស់ទ្រង់ឡើងវិញ។

**ព្រលឹងនៃយើងខ្ញុំឆ្អែតចំពោះសេចក្តីចំអក របស់មនុស្សដែលនៅដោយឥតកង្វល់ នឹងសេចក្តីមើលងាយរបស់មនុស្សឆ្មើងឆ្មៃ (ទំនុកដំកើង១២៣:៤)។**

សាសន៍អ៊ីស្រាអែល ធ្វើដំណើរមកដល់ទីក្រុងយេរូសាឡិម ដែលជាដំណាក់របស់ព្រះជាម្ចាស់ហើយ។ សេចក្តីសង្ឃឹមនៃភ្នែករបស់គេ គឺទុកចិត្តលើព្រះអង្គដែលទ្រង់គង់នៅលើស្ថានសួគ៌។ ខ្ញុំសូមសួរដល់លោកអ្នកនៅថ្ងៃនេះថា តើភ្នែករបស់លោកអ្នកសម្លឹងមើលទៅព្រះជាម្ចាស់ ដែលគង់នៅស្ថានសួគ៌ថា ជាទីសង្ឃឹមរបស់លោកអ្នកដែរឬទេ?

យើងស្លេះការសិក្សាគម្ពីរទំនុកដំកើងត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"